**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
******

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
******

# ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសមជាមួយ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន

នៅព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ**ឯកឧត្តមបណ្ឌិត** Park Heung-kyeong ឯកអគ្គរដ្ឋទូតថ្មីនៃសាធារណរដ្ឋកូរ៉េប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម នៅទីស្តីការក្រសួង ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍ និងអបអរសាទរដល់ **ឯកឧត្តមបណ្ឌិត** Park Heung-kyeong ដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតថ្មីនៃសាធារណរដ្ឋកូរ៉េប្រចាំរាជាណាចក្រកម្ពុជា និងបានសម្តែងការជឿជាក់ថាទំនាក់ទំនងរវាងប្រទេសទាំងពីរនឹងត្រូវបានពង្រឹងពង្រីកឲ្យកាន់តែរឹងមាំក្នុងអាណត្តិការងាររបស់ឯកឧត្តម Park Heung-kyeong ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលឹកអំពី ព្រឹត្តិការណ៍សំខាន់ៗក្នុងឆ្នាំ ២០១៩ ដែលបានធ្វើកិច្ចសហប្រតិបត្តិការ រវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ កាន់តែមានភាពស៊ីជម្រៅ និងទូលំទូលាយទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ជាពិសេសទស្សនកិច្ចផ្លូវរដ្ឋរបស់ប្រធានាធិបតី MoonJae-in នៅកម្ពុជា ក្នុងខែមីនា២០១៩ និងជំនួបរវាង**ឯកឧត្តម** ជាមួយលោកជំទាវរដ្ឋមន្ត្រីការបរទេស Kang Kyung-wha នាឱកាសអញ្ជើញចូលរួមកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សាធារណរដ្ឋកូរ៉េ និងកិច្ចប្រជុំកំពូលមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី១ នៅទីក្រុងប៊ូសាន ពីខែវិច្ឆិកា ២០១៩ ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី**។

ជាការឆ្លើយតប**ឯកឧត្តម** Park Heung-kyeong បានសម្តែងនូវសេចក្តីរីករាយដោយបានទទួលការតែងតាំងជាឯកអគ្គរដ្ឋទូតប្រចាំកម្ពុជា ក្នុងដំណាក់កាលដែលទំនាក់ទំនងរវាងប្រទេសទាំងពីរកំពុងមានការរីកចម្រើនជាខ្លាំង។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ក៏បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជាដែលបានជម្រុញឲ្យកិច្ចប្រជុំកំពូលទាំងពីរនៅក្រុងប៊ូសាន ប្រព្រឹត្តិទៅបានដោយជោគជ័យ ហើយនិងបានគាំទ្រគំនិតផ្តួចផ្តើមរបស់សាធារណរដ្ឋកូរ៉េដើម្បីរួមគ្នាកសាងសន្តិភាពនៅឧបទ្វីបកូរ៉េ និងនាំមកនូវវិបុលភាពសម្រាប់ប្រជាជនក្នុងតំបន់ទាំងមូល។

ពាក់ព័ន្ធនឹងទំនាក់ទំនងទ្វេភាគី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានពិភាក្សាអំពីការខិតខំជំរុញកំណើនពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងកិច្ចសហប្រតិបត្តិការក្នុងវិស័យកសិកម្ម និងវប្បធម៌ ឲ្យស័ក្តិសមនឹងសក្តានុពលនៃប្រទេសទាំងពីរ ដោយអនុវត្តឲ្យមានប្រសិទ្ធភាព

នូវរាល់កិច្ចព្រមព្រៀង រួមទាំងឯកសារចំនួន៥ ដែលទើបបានចុះហត្ថលេខាកាលពីខែវិច្ឆិកា ២០១៩ ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នា ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ កិច្ចសហប្រតិបត្តិការក្នុងវិស័យកសិកម្ម និង បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងការចាប់ផ្តើមការសិក្សារួមគ្នាលើលទ្ធភាពបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ថ្លែងអំណរគុណសាធារណរដ្ឋកូរ៉េដែលបានសម្រេចបង្កើនថវិកាសម្រាប់កិច្ចសហប្រតិបត្តិអភិវឌ្ឍន៍ ហើយបានផ្លាស់ប្តូរយោបល់ជាមួយ**ឯកឧត្តមឯកអគ្គរដ្ឋទូត** អំពីកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន-សាធារណរដ្ឋកូរ៉េ និង មេគង្គ-សាធារណរដ្ឋកូរ៉េ ដោយផ្តោតលើសារៈសំខាន់នៃគំរោងមួយចំនួនស្នើឡើងដោយសាធារណរដ្ឋកូរ៉េ ក្នុងគោលបំណងធ្វើឲ្យកិច្ចសហប្រតិបត្តិការរវាងអាស៊ាន-កូរ៉េ និងមេគង្គ-កូរ៉េ កាន់តែទូលំទូលាយ និងស៊ីជម្រៅ ស្របតាមស្មារតីនៃសេចក្តីថ្លែងការណ៍នៅទីក្រុងប៊ូសាន ដែលផ្អែកលើសសរស្តម្ភបី គឺ ប្រជាជន វិបុលភាព និងសន្តិភាព។

ឆ្លៀតក្នុងឱកាសនោះផងដែរ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និង **ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានពិភាក្សាអំពីបញ្ហាតំបន់ និងអន្តរជាតិ ដែលជាកង្វល់រួមរបស់ប្រទេសទាំងពីរ និងការរៀបចំកិច្ចប្រជុំកំពូលអាស៊ីអឺរ៉ុបលើកទី១៣ នៅទីក្រុងភ្នំពេញ នាឆ្នាំ២០២០ ខាងមុខនេះ។